**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

CAMBODIA

Kingdom of Wonder

feel the warmth

**ក្រសួងទេសចរណ៍**

លេខ ០១១ សរណន

ថ្ងៃអង្គារ ៨រោច ខែស្រាពណ៍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស២៥៦៥

រាជធានីភ្នំពេញ, ថ្ងៃទី ៣១ ខែ សីហា ឆ្នាំ២០២១

# សារាចរណែនាំ

## ស្ដីពី

## ការអនុវត្តប្រកាសលេខ ០៨៣ ប្រក. ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០២១ ស្ដីពី "ការធ្វើបច្ចុប្បន្នភាពវិធានសុវត្ថិភាពទេសចរណ៍សម្រាប់អាជីវកម្មភោជនីយដ្ឋាន អាហារដ្ឋានទេសចរណ៍"

ក្នុងគោលបំណងជួយសម្រួលដល់មូលដ្ឋានអាជីវកម្មទេសចរណ៍ ដែលកំពុងដំណើរការចូលរួមបង្ការ ការពារ និង រក្សាបាននូវសុវត្ថិភាព ទំនុកចិត្ត និងផ្ដល់ភាពកក់ក្ដៅជូនភ្ញៀវទេសចរក្នុងស្រុក ក្រសួងទេសចរណ៍បានប្រកាសឱ្យអនុវត្តនូវ "**វិធានសុវត្ថិភាពទេសចរណ៍**" ចំពោះសេវាកម្មទេសចរណ៍ចំនួន ០៦ ក្នុងនោះរួមមាន "**វិធានសុវត្ថិភាពទេសចរណ៍សម្រាប់សេវាកម្មភោជនីយដ្ឋាន និងអាហារដ្ឋានទេសចរណ៍**" ផងដែរ។

ស្របពេលដែលរាជរដ្ឋាភិបាល បាននិងកំពុងអនុវត្តយ៉ាងសកម្មនូវយុទ្ធនាការជាតិចាក់វ៉ាក់សាំងកូវីដ-១៩ និងជម្រុញផ្សព្វផ្សាយឱ្យប្រជាពលរដ្ឋទាំងអស់ប្រកាន់ឱ្យបានខ្ជាប់ខ្ជួននូវវិធានការ "៣ការពារ ៣កុំ" ដើម្បីចូលរួមទប់ស្កាត់ការរីករាលដាលជំងឺកូវីដ-១៩នៅក្នុងសហគមន៍ ក្រសួងទេសចរណ៍បានពិនិត្យនិងធ្វើបច្ចុប្បន្នភាពលក្ខខណ្ឌនៃការអនុវត្តមួយចំនួន ឆ្លើយតបទៅនឹងគន្លងប្រក្រតីភាពថ្មីនិងស្ថានភាពនាពេលបច្ចុប្បន្ន។

ក្នុងន័យនេះ ក្រសួងទេសចរណ៍ សូមធ្វើការណែនាំដល់ម្ចាស់អាជីវកម្មភោជនីយដ្ឋាន អាហារដ្ឋានទេសចរណ៍ទាំងអស់ ត្រូវបន្តយកចិត្តទុកដាក់រៀបចំការអនុវត្តឱ្យបានម៉ឺងម៉ាត់នូវខ្លឹមសារប្រកាសលេខ ០៨៣ ប្រក. ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០២១ ស្ដីពី "ការធ្វើបច្ចុប្បន្នភាពវិធានសុវត្ថិភាពទេសចរណ៍សម្រាប់សេវាកម្មភោជនីយដ្ឋាន និងអាហារដ្ឋានទេសចរណ៍" ដូចខាងក្រោម៖

១.១. អាជីវកម្មភោជនីយដ្ឋាន និងអាហារដ្ឋានទេសចរណ៍ទាំងអស់ ត្រូវដាក់ពាក្យស្នើសុំលិខិតបញ្ជាក់ និងឡាបិលអំពីការអនុវត្តវិធានសុវត្ថិភាពទេសចរណ៍ តាមរយៈមន្ទីរទេសចរណ៍រាជធានី ខេត្ត និងត្រូវខិតខំរៀបចំកែសម្រួលបរិវេណ និងបែបបទការងាររបស់ខ្លួនឱ្យបានសមស្របទៅនឹងការកំណត់ជាលក្ខណវិនិច្ឆ័យនីមួយៗ នៃវិធានសុវត្ថិភាពទេសចរណ៍។

១.២. ត្រូវរៀបចំផែនការកែតម្រូវសម្បទាអាជីវកម្មរបស់ខ្លួនឱ្យស្របនឹងលក្ខខណ្ឌតម្រូវ និងចំនុចណែនាំទាំងឡាយដូចមានកំណត់ក្នុងខ្លឹមសារប្រកាសលេខ ០៨៣ ប្រក. ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០២១ ស្ដីពី "ការធ្វើបច្ចុប្បន្នភាពវិធានសុវត្ថិភាពទេសចរណ៍សម្រាប់សេវាកម្មភោជនីយដ្ឋាន និងអាហារដ្ឋានទេសចរណ៍"។ រាល់ម្ចាស់អាជីវកម្មត្រូវចាត់ទុកលក្ខខណ្ឌទាំងនោះ ជាគោលការណ៍ណែនាំចម្បងសម្រាប់ការអនុវត្តក្នុងដំណាក់កាលនេះ និងត្រូវអនុវត្តឱ្យបានហ្មត់ចត់និងប្រកបដោយស្មារតីទទួលខុសត្រូវ។

ដីឡូត៍លេខ៣A ផ្លូវលេខ១៦៩ សង្កាត់វាលវង់ ខណ្ឌ៧មករា រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ: +៨៥៥ ២៣ ៨៨៤ ៩៧២ ទូរសារ: +៨៥៥ ២៣ ៨៨៤ ៩៧៤ E-mail: admin@mot.gov.kh Website: www.tourismcambodia.org

១.៣. ត្រូវមានស្មារតីភ្ញាក់រលឹក គិតគូរអំពីបញ្ហាសុវត្ថិភាពភ្ញៀវ សុវត្ថិភាពបុគ្គលិក និងសុវត្ថិភាពសង្គមជាតិជាអាទិភាពចំពោះមុខ។ រាល់ម្ចាស់អាជីវកម្មត្រូវហ៊ានលះបង់ធនធាន កម្លាំង និងពេលវេលា ដើម្បីត្រៀមលក្ខណៈសម្បត្តិឱ្យបានសមស្រប នឹងលក្ខខណ្ឌតម្រូវមុននឹងសម្រេចធ្វើប្រតិបត្តិការអាជីវកម្មរបស់ខ្លួន។

១.៤. ត្រូវរៀបចំឱ្យមានការបណ្តុះបណ្តាលបុគ្គលិករបស់ខ្លួនឱ្យបានជាប់ជាប្រចាំ អំពីវិធានការ “**៣ការពារ ៣កុំ**” អំពីវិធានការផ្សេងទៀតសំដៅបង្ការនិងទប់ស្កាត់ការរីករាលដាលជំងឺកូវីដ-១៩អំពី របៀបកំណត់អត្តសញ្ញាណបុគ្គលសង្ស័យមានផ្ទុកមេរោគកូវីដ-១៩ និងអំពីរបៀបរាយការណ៍អំពីករណីសង្ស័យជាដើម។

១.៥. ត្រូវចូលរួមផ្សព្វផ្សាយរាល់វិធានការនានាដែលបានដាក់ចេញដោយរាជរដ្ឋាភិបាល និងក្រសួង ស្ថាប័នមានសមត្ថកិច្ច ដែលសំដៅបង្ការនិងទប់ស្កាត់ការរីករាលដាលជំងឺកូវីដ-១៩

១.៦. ត្រូវបង្កលក្ខណៈងាយស្រួល និងជម្រុញឱ្យបុគ្គលិករបស់ខ្លួនទាំងអស់ រួមទាំងក្រុមគ្រួសាររបស់ពួកគាត់ទៅទទួលយកការចាក់វ៉ាក់សាំងប្រឆាំងនឹងជំងឺកូវីដ-១៩ ឱ្យបានគ្រប់គ្នា និងឱ្យបានគ្រប់ចំនួនដូសតាមការកំណត់។

១.៧. ត្រូវអនុវត្ត និងប្រើប្រាស់ឱ្យបានត្រឹមត្រូវនូវគ្រប់ប្រព័ន្ធបច្ចេកវិទ្យាដែលបានដាក់ឱ្យអនុវត្តកន្លងមកដោយរាជរដ្ឋាភិបាល និងក្រសួងស្ថាប័នពាក់ព័ន្ធ រួមមានៈ ការស្កេន QR Code ទប់ស្កាត់កូវីដ១៩ និងប្រព័ន្ធ Telegram BOT គ្រប់គ្រងទិន្នន័យភ្ញៀវក្នុងឧស្សាហកម្មទេសចរណ៍ជាដើម។

ក្រសួងទេសចរណ៍ សូមណែនាំអំពីការអនុវត្តខ្លឹមសារប្រកាសខាងលើ ជាដំណាក់កាល ដូចខាងក្រោមៈ

**ដំណាក់កាលទី១** ៖ ចាប់ពីថ្ងៃចុះហត្ថលេខា គ្រប់អាជីវកម្មភោជនីយដ្ឋាន និងអាហារដ្ឋានទេសចរណ៍ទាំងអស់ ត្រូវចូលរួមអនុវត្តប្រកាសខាងលើក្រោមទម្រង់ជាការជម្រុញ និងលើកទឹកចិត្ត។

**ដំណាក់កាលទី២** ៖ បន្ទាប់ពីថ្ងៃចាប់ផ្តើមបើកដំណើរការទេសចរណ៍អន្តរជាតិត្រលប់មកវិញ គ្រប់អាជីវកម្មភោជនីយដ្ឋាន និងអាហារដ្ឋានទេសចរណ៍ទាំងអស់ ត្រូវអនុវត្តខ្លឹមសារប្រកាសខាងលើជាកាតព្វកិច្ច។

ទទួលបានសេចក្តីណែនាំនេះ សូម រដ្ឋបាលរាជធានី ខេត្ត និងម្ចាស់អាជីវកម្មភោជនីយដ្ឋាន និងអាហារដ្ឋានទេសចរណ៍ ត្រូវអនុវត្តសារាចរណែនាំនេះប្រកបដោយស្មារតីទទួលខុសត្រូវ។

**រដ្ឋមន្ត្រី**

**ថោង ខុន**

**__កន្លែងទទួលៈ__**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងសុខាភិបាល
- គណៈកម្មការជាតិប្រយុទ្ធនឹងជំងឺកូវីដ-១៩
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី

*“ដើម្បីជូនជ្រាប”*

- សាលារាជធានី ខេត្ត
- មន្ទីរទេសចរណ៍រាជធានី ខេត្ត

*“ដើម្បីអនុវត្ត”*

- សហព័ន្ធទេសចរណ៍កម្ពុជា
- សមាគមភោជនីយដ្ឋានកម្ពុជា

*“ដើម្បីសហការ”*

- រាជកិច្ច
- ឯកសារ កាលប្បវត្តិ